# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាបុណ្យសន្តហ្វ្រង់ស្វ័រសាវីយេនៅចំប៉ា
# ថ្ងៃទី០៣ ធ្នូ ២០១៧

*ចូរប្រុងស្មារតីស្តាប់*

អត្ថបទទី១៖ អស ៦៣,១៦-១៧.១៩-៦៤,២-៧
អត្ថបទទី២៖ ១ករ ១,៣-៩
ដំណឹងល្អ៖ មក ១៣,៣៣-៣៧

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ ជាអាទិត្យទីមួយនៅក្នុងរដូវរង់ចាំ ពិតមែនយើងមានអារពណ៌ស្វាយ ដូចនៅពេលយើងចូលនៅក្នុងរដូវបុណ្យត្រណម។ ប៉ុន្តែ រដូវរង់ចាំជាបរិយាកាសមួយផ្សេង ពីរដូវត្រណម។ រដូវរង់ចាំ ជាពេលវេលាមួយដែលយើងទន្ទឹងរង់ចាំព្រះយេស៊ូ នៅថ្ងៃបុណ្យព្រះយេស៊ូប្រសូត។ មានន័យថា រដូវរង់ចាំជាពេលវេលាមួយដែលណែនាំឲ្យយើងរំភើបនៅក្នុងអំណរសប្បាយ។ បើយើងសួរម្តាយដែលជិតឆ្លងទន្លេ ខ្ញុំជឿថាគាត់រំភើបផង សប្បាយផង ភ័យផង ដោយសារទន្ទឹងរង់ចាំឃើញមុខកូនគាត់។ សម្រាប់យើងទាំងអស់គ្នាក៏ដូចគ្នាដែរ នៅក្នុងរដូវរង់ចាំយើងសប្បាយផង យើងរំភើបផង ដោយសារយើងទន្ទឹងរង់ចាំមើលព្រះយេស៊ូដែលកំពុងយាងមក មើលព្រះយេស៊ូដែលមកសួរសុខទុក្ខយើង។

**ទីមួយ** រដូវរងចាំ ជាពេលវេលាដែលយើង**ទន្ទឹងរង់ចាំនៅក្នុងអំណរសប្បាយ** ព្រះជាម្ចាស់ដែលយាងមកសួរសុខទុក្ខយើង ព្រះជាម្ចាស់ដែលយាងមកសួរយើង តើយើងកំពុងរៀបចំខ្លួនដូចម្តេច ដើម្បីត្រៀមទទួលជីវិតអស់កល្បជានិច្ច? ថ្ងៃនេះយើងគោរព សន្តហ្វ្រង់ស្វ័រសាវីយេ គាត់មានគំនិតតែមួយគត់ គឺគាត់ចង់ទៅប្រកាសដំណឹងល្អឲ្យប្រជាជននៅប្រទេសចិនឲ្យគេស្គាល់ព្រះយេស៊ូ។ ដូច្នេះគាត់ចេញធ្វើដំណើរពីប្រទេសអេស្ប៉ាញ នៅសម័យនោះអត់មានឡាន អត់មានយន្តហោះ គាត់ជិះសំពៅ ប្រទេសទីមួយដែលគាត់ទៅគឺប្រទេសឥណ្ឌា ដើម្បីប្រកាសដំណឹងល្អ។ គាត់បន្តធ្វើដំណើរពីប្រទេសឥណ្ឌាទៅប្រទេសជប៉ុន គាត់ទៅដោយសួរសុខទុក្ខជនជាតិជប៉ុនដោយនាមរបស់ព្រះជាម្ចាស់ផ្ទាល់ដើម្បីឲ្យគេស្គាល់។ សន្តហ្វ្រង់ស្វ័រសាវីយេ ជាមនុស្សឆ្លាតដោយសារគាត់មិនទៅតែជាមួយប្រជាជនក្រីក្រ ប៉ុន្តែគាត់បង្កើតទំនាក់ទំនងជាមួយរដ្ឋអំណាច ជាមួយស្តេចក្រាញ់នៅខេត្តដែលគាត់គឺនៅកាកូឝីម៉ាក។ ទំនាក់ទំនងដែលគាត់បង្កើតនេះ ណែនាំឲ្យគេពេញចិត្តនឹងគាត់។ គាត់ចាប់ផ្តើមប្រកាសដំណឹងល្អនៅពេលវេលាខ្លីដែលគាត់រស់នៅប្រទេសជប៉ុន។ ដោយសារសន្តហ្វ្រង់ស្វ័រសាវីយេ មានសាមសិបម៉ឺននាក់ដែលទទួលពិធីជ្រមុជទឹកនៅប្រទេសជប៉ុន។ ក្រោយមករដ្ឋអំណាចអត់សប្បាយចិត្តជាមួយគ្រីស្តសាសនា ដោយសារឃើញមានប្រជាជនជប៉ុនច្រើនពេកដែលចាប់ផ្តើមចូលគ្រីស្តសាសនា ដូចច្នេះគេបណ្តេញសាសនៈទូតទាំងអស់។ សន្តហ្វ្រង់ស្វ័រសាវីយេ ចាប់ផ្តើមបន្តធ្វើដំណើរ រហូតគាត់ស្លាប់នៅលើកោះមួយនៅក្បែរប្រទេសចិន។ អ្វីដែលគាត់ធ្វើ

នៅប្រទេសជប៉ុន ដែលមានសាមសិបម៉ឺននាក់ដែលមានជំនឿរឹងមាំ ដោយសារសម័យសន្តហ្វ្រង់ស្វ័រសាវីយេ រដ្ឋអំណាចបណ្ដេញសាសនៈទូតទាំងអស់ ហេតុនេះហើយគ្រីស្តបរិសទ័ឥតមានបូជាចារ្យ ឥតមានបងប្រុសបងស្រី។ រដ្ឋអំណាចចាប់ផ្ដើមសម្លាប់គេអស់២៦នាក់ ដោយឆ្កាងនៅទីក្រុងណាហ្គាសាគី ដោយបានដើរមួយពាន់គីឡូម៉ែត្រនៅក្នុងរដូវរងា ដោយមើលងាយគេ វ៉ៃគេ និងរដ្ឋអំណាចណែនាំជនជាតិជប៉ុនមួយចំនួនធំស្អប់ព្រះយេស៊ូ ស្អប់ព្រះនាងម៉ារី គេដាក់រូបព្រះយេស៊ូ(ឈើឆ្កាង)នៅលើដី នឹងគេថាប្រសិនបើចង់មានជីវិតត្រូវតែជាន់រូបព្រះយេស៊ូ(ឈើឆ្កាង) មានមួយចំនួនគេបង្ខំចិត្តជាន់ មានន័យថានៅក្នុងចិត្តគេមិនចង់ជាន់ព្រះយេស៊ូទេ ប៉ុន្តែគេខ្លាចស្លាប់។ មួយចំនួនទៀតគេមិនព្រមជាន់ ដូច្នេះមួយចំនួននេះគេស្លាប់នឹងបានក្លាយជាមរណៈសាក្សី។ ព្រះយេស៊ូព្រះជាម្ចាស់ តាមរយៈសន្តហ្វ្រង់ស្វ័រសាវីយេបានសួរសុខទុក្ខប្រជាជននៅប្រទេសជប៉ុន ឲ្យគេមានជំនឿរឹងមាំ។

**ទីពីរ** សម្រាប់យើងក៏ដូចគ្នាដែរ នៅក្នុងរដូវរងចាំនេះ**ព្រះជាម្ចាស់កំពុងសួរសុខទុក្ខយើងឲ្យយើងមានសេចក្ដីមានសង្ឃឹម** ប៉ុន្តែដើម្បីទទួលការសួរសុខទុក្ខពីព្រះជាម្ចាស់។ អំបាញ់មិញពេលខ្ញុំដើរតាមផ្ទះនីមួយៗបីដូចជាព្រះជាម្ចាស់តាមរយៈព្រះពរដែលខ្ញុំបានឲ្យ តាមរយៈសន្តហ្វ្រង់ស្វ័រសាវីយេ តាមរយៈអធិដ្ឋាន គឺព្រះជាម្ចាស់ផ្ទាល់ដែលទៅសួរសុខទុក្ខតាមផ្ទះនីមួយៗ។ ខ្ញុំបានឃើញថ្ងៃនេះតាមផ្ទះនីមួយៗបងប្អូនបានរៀបចំអាសនៈតូច រៀបចំផ្កា រៀបចំទៀន រៀបចំផ្ទះ រៀបចំកម្រាលទាំងអស់គ្នាបានយកចិត្តទុកដាក់រៀបចំសម្អាត់ផ្ទះ ដើម្បីស្វាគមន៍ព្រះជាម្ចាស់ដែលយាងមកសួរសុខទុក្ខយើង។ ហេតុនេះហើយ សម្រាប់រដូវរង់ចាំក៏ដូចគ្នាដែរឲ្យយើងយកចិត្តទុកដាក់រៀបចំខ្លួនរបស់យើងមិនមែនតែអាសនៈដែលមានផ្កា ដែលមានទៀន ដែលមានកម្រាល ដែលមានរូបសន្តហ្វ្រង់ស្វ័រសាវីយេ ប៉ុន្តែឲ្យយើងរៀបចំចិត្តគំនិត ឲ្យយើងសម្អាតខាងក្នុងខ្លួនរបស់យើង។ យើងបានសម្អាតផ្ទះរបស់យើងហើយ ឥលូវនេះយើងត្រូវការសម្អាតខាងក្នុងដើម្បីទទួលស្វាគមន៍ព្រះជាម្ចាស់ដែលយាងមកសួរសុខទុក្ខយើង។ ឲ្យយើងយកចិត្តទុកដាក់រៀបចំខាងក្នុង នៅក្នុងរដូវរងចាំដូចព្រះយេស៊ូមានព្រះបន្ទូល **"ខ្ញុំចង់និយាយប្រាប់អ្នកឯទៀតៗគ្រប់គ្នាដែរ គឺចូរប្រុងស្មារតី"** ឲ្យយើងប្រុងស្មារតីដោយអធិដ្ឋាន ចូលអភិបូជារាល់ថ្ងៃ។ ក្មេងៗដែលទទួលព្រះកាយថ្ងៃនេះ សប្បាយចិត្តឬអត់? មិនធម្មតាទេ គឺព្រះយេស៊ូដែលយាងមកសួរសុខទុក្ខផ្ទាល់។ បន្តិចទៀតយើងមាន ព្រះកាយនៅក្នុងខ្លួនគឺព្រះយេស៊ូសួរសុខទុក្ខយើងផ្ទាល់ ហើយយើងត្រូវការបន្តរៀបចំចិត្តគំនិតដោយប្រុងស្មារតីនៅក្នុងការអធិដ្ឋាននិងនៅក្នុងការបម្រើ។

**ទីបី** ដែលសំខាន់បំផុតសម្រាប់យើងនៅរដូវរងចាំ **ឲ្យយើងថែរក្សាសេចក្ដីសង្ឃឹមជានិច្ច** មើលសន្តហ្វ្រង់ស្វ័រសាវីយេ គាត់តស៊ូណាស់នៅពេលគាត់ទៅឥណ្ឌា ក្រោយមកគាត់បន្តធ្វើដំណើរ

ទៅប្រទេសជប៉ុនគាត់តស៊ូច្រើន ក្រោយមកគេបណ្តេញគាត់ទៅដល់កោះមួយក្បែរប្រទេសចិន ដោយសារគាត់មានសេចក្តីសង្ឃឹមជានិច្ច និងក្តីសង្ឃឹមរបស់គាត់គឺចូលទៅប្រទេសចិនដើម្បីឲ្យជនជាតិចិនស្គាល់ព្រះយេស៊ូ។ គាត់ធ្វើមិនបានគាត់ស្លាប់មុន ប៉ុន្តែអស់មួយជីវិតរបស់គាត់ គាត់បានទៅមុខជានិច្ច គាត់បានឈ្នះឧបសគ្គទាំងអស់ដោយសារគាត់ថែរក្សាសេចក្តីសង្ឃឹម។ ដូច្នេះយើងដឹងហើយយើងបានតស៊ូច្រើនដែរ យើងមានទុក្ខលំបាកមួយចំនួនធំដែរ យើងឈ្នះទុក្ខលំបាកនេះ ឈ្នះអ្វីៗទាំងអស់ដែលធ្វើឲ្យយើងពិបាកដោយសារជំនឿរបស់យើង ណែនាំឲ្យយើងមានសេចក្តីសង្ឃឹមជានិច្ច។

រដូវរងចាំជាពេលវេលាមួយ ដើម្បីថែរក្សាសេចក្តីសង្ឃឹមនេះ ដោយសារយើងដឹងថានៅក្នុងបីអាទិត្យយើងគោរពព្រះយេស៊ូប្រសូត្រ ព្រះយេស៊ូដែលជាពន្លឺសម្រាប់ពិភពលោកទាំងមូល។ នៅប្រទេសភូមា យើងបានជួបជាមួយសម្តេចប៉ាបហ្វ្រង់ស៊ីស្កូ បីដង។ នៅថ្ងៃដែលសម្តេចប៉ាប យាងមកដល់ភូមា យើងបានចូលរួមអភិបូជាពីរដង នៅពេលនោះយើងឃើញប្រទេសភូមាជាប្រទេសមួយក្រីក្រ ប៉ុន្តែគ្រីស្តបរិស័ទបានធ្វើដំណើរជូនកាលបីថ្ងៃបួនថ្ងៃដើម្បីជួបជុំគ្នា ដើម្បីស្តាប់សម្តេចប៉ាប និងដើម្បីទទួលព្រះពរពីសម្តេចប៉ាប។ មានខ្លះគេនៅក្នុងព្រៃ គេនៅលើភ្នំ គេឥតសូវមានផ្លូវគេដើរមួយថ្ងៃពីរថ្ងៃឥតសូវមានម្ហូប តែគេតស៊ូដើម្បីទទួលព្រះពរពីសម្តេចប៉ាប ដោយសារសម្តេចប៉ាបបានណែនាំឲ្យគេមានសេចក្តីសង្ឃឹម ដោយយល់ថាជីវិតយើងជាគ្រីស្តបរិស័ទពោរពេញដោយអំណរសប្បាយ ដោយសារយើងមានព្រះយេស៊ូដែលថែរក្សាយើង ដោយសារយើងមានទីពឹងមួយយ៉ាងពិសេសយើងដឹងថាយើងទីពឹងលើព្រះយេស៊ូជានិច្ច។

ដូច្នេះតាមរយៈអភិបូជានេះ ខ្ញុំជូនការសុខទុក្ខពីសម្តេចប៉ាបផ្ទាល់ ជូនព្រះពរពីសម្តេចប៉ាបដល់បងប្អូនទាំងអស់ ដោយយើងដឹងថាយើងជាគ្រីស្តបរិស័ទនៅព្រះសហាគមន៍ចំប៉ា នៅមណ្ឌលសកម្មភាពទន្លេមេគង្គធ្វើយ៉ាងម៉េចដើម្បីថែរក្សាសេចក្តីសង្ឃឹមជានិច្ច។ ហេតុនេះហើយរដូវរងចាំនេះបីចំនុចខាងលើមាន អំណរសប្បាយដោយសារព្រះជាម្ចាស់មកសួរសុខទុក្ខយើង យកចិត្តទុកដាក់ដើម្បីរៀបចំខ្លួនដោយអធិដ្ឋាននិងបម្រើ និងថែរក្សាសេចក្តីសង្ឃឹមជានិច្ចនៅក្នុងសេចក្តីស្រឡាញ់ ដោយដឹងថាជីវិតរបស់យើងមានពន្លឺជានិច្ចពីព្រោះព្រះយេស៊ូយាងមក និងព្រះយេស៊ូស្រឡាញ់យើង នេះជាសេចក្តីសង្ឃឹមរបស់យើង។

ថ្ងៃនេះយើងអធិដ្ឋាន អរព្រះគុណព្រះជាម្ចាស់ឲ្យព្រះអង្គប្រទានពរដល់បងប្អូនទាំងអស់ក្រុមគ្រួសារយើងទាំងអស់នៅក្នុងឆ្នាំនៃគ្រួសារ និងឲ្យព្រះអង្គជួយលើកទឹកចិត្តកូនៗដែលទទួលព្រះកាយថ្ងៃនេះ ហើយកុំភ្លេចចូលអភិបូជារាល់អាទិត្យ។ សូមឪពុកម្តាយ លោកតាលោកយាយជួយប្រមូលកូនក្មេងឲ្យចូលអភិបូជារាល់អាទិត្យ។ ដូច្នេះ ឪពុកម្តាយជួយបំភ្លឺកូនៗពេលទទួលព្រះ

កាយហើយចូលអភិបូជាជារៀងរាល់អាទិត្យៗ។ ដូច្នេះឲ្យយើងយកចិត្តទុកដាក់ ដើម្បីទទួលព្រះកាយថ្ងៃនេះ ប៉ុន្តែយើងទទួលរាល់អាទិត្យ មានន័យថាយើងទទួលព្រះយេស៊ូផ្ទាល់។ យើងអរព្រះគុណព្រះជាម្ចាស់ សូមវិញ្ញាណដ៏វិសុទ្ធបំភ្លឺយើង ដើម្បីស្តាប់ព្រះបន្ទូលរបស់ព្រះយេស៊ូ ខ្ញុំក៏ចង់និយាយប្រាប់អ្នករាល់គ្នា គឺចូរប្រុងស្មារតីស្តាប់។ អាម៉ែន៕